ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ :...៩៥១.....អ.រតន.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ............ខែ ........ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០៧ខែមករា ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើស បុគ្គលិកជាប់កិច្ចសន្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយកដ្ឋានរតនាគារជាតិ គឺជាបេឡាករ និងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា តែមួយគត់។ ជាមួយនឹងកំណើននៃប្រតិបត្តិការគណនេយ្យ-ហិរញ្ញវត្ថុរបស់រដ្ឋ នាយកដ្ឋានគណនេយ្យ នៃអគ្គនាយកដ្ឋានរតនាគារជាតិមានតម្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន **០១ រូប** ជា **ជំនួយការគណនេយ្យ** ដើម្បីបំពេញភារកិច្ច ដូចខាងក្រោម÷

**១. តួនាទីភារកិច្ចសំខាន់ៗ**

- ចុះកិច្ចបញ្ជិកាគណនេយ្យ នូវប្រតិបត្តិការហិរញ្ញវត្ថុ ប្រចាំថ្ងៃ របស់រដ្ឋ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ Financial Management Information System (FMIS)
- ចូលរួមផ្ទៀងផ្ទាត់ទិន្នន័យ និងជួយរៀបចំបញ្ជីវិភាគគណនី ក្នុងប្រព័ន្ធ FMIS
- ចូលរួមរៀបចំនិងរក្សាទុកដាក់សក្ខីបត្រគណនេយ្យ ឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា
- ចូលរួមរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗ ប្រចាំថ្ងៃ ខែ និងឆ្នាំ តាមតម្រូវការចាំបាច់
- ជួយការងារពាក់ព័ន្ធផ្សេងៗទៀត តាមការចាំបាច់។

**២. លក្ខខណ្ឌនៃការជ្រើសរើស**

- បេក្ខជនទាំងពីរភេទត្រូវមានបរិញ្ញាបត្រ ឬ ជានិស្សិតឆ្នាំទី៤ ជិតបញ្ចប់ការសិក្សា ផ្នែក ***គណនេយ្យ ឬ ហិរញ្ញវត្ថុ***
- ចេះភាសាអង់គ្លេស និង កម្មវិធី Ms Office និង/ឬ កម្មវិធី គណនេយ្យផ្សេងទៀត
- មានភាពអត់ធ្មត់ក្នុងការងារ, អាចធ្វើការងារជាក្រុម, ចេះច្នៃប្រឌិតការងារ និងវៃឆ្លាតក្នុងការចូលរួមដោះស្រាយបញ្ហា។

**៣. ព័ត៌មាននៃការដាក់ពាក្យស្នើសុំ**

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ និងមានកម្រិតវប្បធម៌ ដូចបានរៀបរាប់ខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេបមកកាន់អាសយដ្ឋាន ដូចខាងក្រោម÷

អគ្គនាយកដ្ឋានរតនាគារជាតិ អគារលេខ ១៩ វិថីព្រះមហាក្សត្រីយានីកុសមៈ (ផ្លូវលេខ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីម៉ែល lyna.seng27@gmail.com ។ កាលបរិច្ឆេទឈប់ទទួលពាក្យ **នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៧:៣០នាទី**។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង **លោកស្រី សេង លីណា** តាមរយៈលេខទូរស័ព្ទ **០១១ ៦៣៧ ៣១១**។

**អគ្គនាយកដ្ឋានរតនាគារជាតិ**